ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខៈ ១៣៥៦ សក

# សូមគោរពជូន
# សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**កម្មវត្ថុៈ** សូមគោរពស្នើសុំពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់ចុះហត្ថលេខា លើអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។

**យោងៈ** ព្រះរាជក្រឹត្យលេខនស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយស សូមគោរពជម្រាបជូន **សម្តេច អគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា យោងមាត្រា៨ នៃព្រះរាជក្រឹត្យលេខន ស/រកត/ ០៦១៤/៨០៨ ខាងលើ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស **គ.ជ.ប.ជ** ត្រូវមានអគ្គលេខាធិការដ្ឋាន មួយជាអង្គភាពប្រតិបត្តិ ដែលការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.ប.ជ** ត្រូវកំណត់ដោយអនុក្រឹត្យ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់ ចុះហត្ថលេខាលើអនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនេះ ដោយក្តីអនុគ្រោះ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០១៤
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**